# I ទីស្ដីការគណៈរដ្ឋមន្ត្រី

## ១. អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៤

### អនុក្រឹត្យលេខ ០២ អនក្រ ស្ដីពីការបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះ អន្តរក្រសួងទប់ស្កាត់បទល្មើសព្រៃឈើ . បទល្មើសនេសាទ . បទល្មើស កាប់ដើមកៅស៊ូ និង ដឹកជញ្ជូនជ័រកៅស៊ូ

* * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័នព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្ដីប្រកាស នៃ រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា លេខ ០៣ សប្រក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩៣ ស្ដីពីការទប់ស្កាត់បទល្មើសវិស័យកៅស៊ូ
- យោងសារាចររាជរដ្ឋាភិបាលកម្ពុជា លេខ ១៥ ស.រ ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៩៣ ស្ដីពីការទប់ស្កាត់បទល្មើសនេសាទ និង បទល្មើសព្រៃឈើ
- តាមសំណើរបស់មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

ប្រការ ១ ៖ បង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះអន្តរក្រសួងដែលមានសមាសភាពដូចខាងក្រោម ៖

១ - ឯកឧត្ដម តាវ សេងហួរ រដ្ឋលេខាធិការ ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ប្រធាន

២ - ឯកឧត្ដម ខាត់ សាវឿន រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ អនុប្រធាន

៣ - ឯកឧត្តម ចាយ សាំងយុន រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

៤ - ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាន សមាជិក

៥ - ឯកឧត្តម លូ ឡាយស្រេង អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

៦ - ឯកឧត្តម ជា ប៉េងឈាង អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

ប្រការ ២ ៖ គណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះអន្តរក្រសួងមានភារកិច្ចដូចតទៅ ៖

១ - លើកវិធានការណ៍ និង ចាត់ចែងកំលាំងទប់ស្កាត់ និង បង្ក្រាបបទល្មើសទាំងឡាយដូចមានចែងខាងលើ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

២ - តាមដាន និង ត្រួតពិនិត្យការអនុវត្តន៍ច្បាប់ និង បទបញ្ញត្តិផ្សេងៗ ដែលទាក់ទងនឹងវិស័យ ព្រៃឈើ - នេសាទ - កៅស៊ូ

៣ - វាយការណ៍ និង វាយតំលៃសភាពការណ៍ និង លទ្ធផលនៃការបង្ក្រាបបទល្មើសនេសាទ - បទល្មើសព្រៃឈើ និង ការកាប់ដើមកៅស៊ូ ដឹកជញ្ជូនជ័រកៅស៊ូខុសច្បាប់ ជូនរាជរដ្ឋាភិបាលកម្ពុជា ។

ប្រការ ៣ ៖ គណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះអន្តរក្រសួងនេះ មានលេខាធិការដ្ឋានជាសេនាធិការ ដើម្បីជួយការងារក្នុងការអនុវត្តភារកិច្ចជាក់ស្តែង ក្នុងការរាល់ឧបសគ្គទប់ស្កាត់បទល្មើសទាំងឡាយខាងវិស័យព្រៃឈើ - នេសាទ - កៅស៊ូ ។

សមាសភាពនៃលេខាធិការដ្ឋានមានដូចខាងក្រោមនេះ ៖

១ - ឯកឧត្តម ម៉ៅ សំអឿន អនុរដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ប្រធាន

២ - ឯកឧត្តម សរ បូ នាយកទីចាត់ការគយ និង រដ្ឋាករ សមាជិក

៣ - ឧត្តមសេនីយត្រី ពៅ សើទមី ក្រសួងមហាផ្ទៃ សមាជិក

៤ - ឧត្តមសេនីយទោ ភួង ប៊ុនធឿន កងរាជអាវុធហត្ថ សមាជិក

៥ - ឧត្តមសេនីយឯក យឹម សារី នាយកកស្តុភារអគ្គសេនាធិការដ្ឋាន សមាជិក

៦ - លោក តេង ឡាវ អគ្គនាយកដ្ឋានចំការកៅស៊ូ សមាជិក

៧ - លោក លី ផល្លា នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស សមាជិក

៨ - លោក ប៊ូ សេងជី នាយកដ្ឋានជលផល សមាជិក

៩ - លោក ចាន់ ឃន នាយកដ្ឋានរុក្ខាប្រមាញ់ សមាជិក

ប្រការ ៤ ៖ សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និង លេខាធិការដ្ឋាន ត្រូវចូលរួមធ្វើការងារតាមការ